# ស្ទឹងសែន/សន្ទុក/បារាយណ៍ A1, A3 & A4i



**ខេត្ត** : កំពង់ធំ កំពង់ចាម និង កំពង់ឆ្នាំង

**ស្រុក** : កំពង់ស្វាយ សន្ទុក ស្ទឹងសែន បារាយណ៍ បាធាយ ជលគីរី និង កំពង់ឡែង

**ផ្ទៃដី ( ហិកតា)** : ១០៩.៣៨១

**រយៈកំពស់ ( ម៉ែត្រ)** : ៤ ដល់ ១៦

**កូអរដោនេចំណុចកណ្ដាល** : ១២°២៥´ជ ១០៤°៥៣´ក

## ការពិពណ៌នាទីកន្លែង

តំបន់ IBA នេះ ស្ថិតនៅប៉ែកខាងត្បូងនៃទីរួមខេត្តកំពង់ធំនៅក្នុងតំបន់លិចទឹកបឹងទន្លេសាប ។ តំបន់នេះ គឺជាតំបន់មួយដែលមានវាលស្មៅលិចទឹកតាមរដូវកាលធំជាងគេបំផុតនៅក្នុងតំបន់វាលទំនាបលិចទឹកបឹងទន្លេសាប ដែលគេបានធ្វើស្រូវឡើងទឹកនៅចុងតំបន់ប៉ែកខាងកើត និង ខាងជើង ។ ប្រភេទទីជំរកទាំងនោះដុះលាយឡំជាមួយព្រៃគុម្ពោត វាលភក់មានឈូកដុះ និង រុក្ខជាតិកក់ បបុស ត្រែង ហើយនៅរដូវប្រាំង មានបឹងតូច ធំជាច្រើន ។ កំពស់ទឹកមានកំរិតខ្ពស់នៅរដូវវស្សា (ពីខែសីហា-តុលា) តំបន់នេះទាំងមូលត្រូវបានលិចទឹក ។ ផ្នែកខ្លះនៃតំបន់នេះស្ថិតនៅក្នុងតំបន់ប្រើប្រាស់ច្រើនយ៉ាងបឹងទន្លេសាប ដែលកំណត់ដោយព្រះរាជក្រឹត្យជាតំបន់ការពារនៅឆ្នាំ ១៩៩៣ និង តំបន់ឋបនីយជីវមណ្ឌលបឹងទន្លេសាប ។

តំបន់ IBA នេះ គឺជាទីកន្លែងពងកូនដ៏មានសារៈសំខាន់ណាស់សម្រាប់សត្វខ្សឹប ក្នុងរដូវប្រាំង (ពីខែ ធ្នូ-ឧសភា) ។ នៅក្នុងរដូវវស្សា (ពីខែ ឧសភា-កក្កដា) មានសត្វស្លាបទឹកមួយចំនួនបានមករកស៊ី និង ស្នាក់អាស្រ័យនៅក្នុងតំបន់នេះរួមមាន ត្រដក់ រនាលពណ៌ និង ចង្កៀលខ្យង ។ លើសពីនេះទៀត តំបន់នេះបានទ្រទ្រង់ចាបដូនតាវាលស្រែជាច្រើនក្បាល ព្រមទាំងអកខ្មៅដីសើមមួយចំនួនតូច និង ឥន្ទ្រីយ៍ ដែលជាពពួកអន្តោប្រវេសន៍ ។ សំខាន់បំផុតនោះ តំបន់នេះបានទ្រទ្រង់ចំនួនត្រយ៉ងចំកំកសជាច្រើនក្បាល ដែលគេបានកត់ត្រាក្នុងប្រទេសកម្ពុជានៅក្នុងទសវត្សថ្មីៗនេះ គឺបានសង្កេតឃើញនៅទីនោះនៅឆ្នាំ ១៩៩៩ ។

## ប្រភេទសត្វស្លាបសំខាន់ៗ

| ឈ្មោះខ្មែរ | ឈ្មោះអង់គ្លេស | ឈ្មោះវិទ្យាសាស្ត្រ | លក្ខណៈវិនិច្ឆ័យIBA | |
|---|---|---|---|---|
| ក្រៀល | Sarus Crane | *Grus antigone* | A1 | |
| ខ្សឹប | Bengal Florican | *Houbaropsis bebgalensis* | A1 | |
| ចាបដូនតាវាលស្រែ | Manchurian Reed Warbler | *Acrocephalus tangorum* | A1 | |
| ចាបពួកទ្រូងលឿង | Asian Golden Weaver | *Ploceus hypoxanthus* | A1 | |
| ចង្កៀលខ្យង | Asian Openbill | *Anastomus oscitans* | | A4i |
| ត្រដក់តូច | Lesser Adjutant | *Leptoptilos javanicus* | A1 | |
| ត្រដក់ធំ | Greater Adjutant | *Leptoptilos dubius* | A1 | A4i |
| ត្រយ៉ងខ្លួន ស | Black-headed Ibis | *Threskiornis melanocephalus* | A1 | |
| ត្រយ៉ងចំកំក ស | White-shouldered Ibis | *Pseudibis davisoni* | A1 | |

| | | | |
|---|---|---|---|
| ទុងប្រផេះ | Spot-billed Pelican | *Pelecanus philippensis* | A1 |
| រនាលពណិ | Painted Stork | *Mycteria leucocephala* | A1 |
| រនាល ស | Milky Stork | *Mycteria cinerea* | A1 |
| អកខ្មៅដីសើម | Greater Spotted Eagle | *Aquila clanga* | A1 |
| អកត្រីក្បាលប្រផេះ | Grey-headed Fish Eagle | *Ichthyophaga ichthyaetus* | A1 |
| អង្កត់ខ្មៅ | Black-necked Stork | *Ephippiorhynchus asiaticus* | A1 |
| ឥន្ទ្រីយ៍ | Imperial Eagle | *Aquila heliaca* | A1 |

**ប្រភេទសត្វប្រមូលផ្តុំក្នុងតំបន់មួយជាក់លាក់**

មានសត្វស្លាបមួយប្រភេទរស់នៅក្នុងប្រភេទព្រៃរបោះ និង មួយប្រភេទរស់នៅក្នុងតំបន់ទំនាបវាលស្មៅ (សូមមើលតារាងឧបសម្ព័ន្ធ៤) ។

**ប្រភេទពានរជាតិទទួលរងការគំរាមកំហែងពិភពលោក**

ស្វាក្តាម និង ស្វាព្រាម ។

**ការគំរាមកំហែងលើជីវៈចំរុះ**

ទោះជាមិនមានលំនៅដ្ឋានរបស់មនុស្សជាអចិន្ត្រៃយ៍នៅក្នុងតំបន់វាលស្មៅលិចទឹកតាមរដូវកាលក៏ដោយ មានភូមិ និង ដីស្រែមួយចំនួននៅក្នុងតំបន់លិចទឹកនោះដែរ ។ ក្នុងរដូវប្រាំងនៅពេលដែលទឹកបានស្រកចុះ មានប្រជាជនជាច្រើនបានធ្វើដំណើរទៅកាន់តំបន់លិចទឹកពីតំបន់ក្រៅៗដែលស្ថិតនៅប្រហែលជាង៥០គីឡូម៉ែត្រ ដើម្បីធ្វើការនេសាទ ច្រូតស្មៅ កាប់អុស និង ដាំដំណាំនៅក្នុងតំបន់ដីសើម ព្រមទាំងឃ្វាលគោ ក្របីរាប់រយក្បាល ។ សកម្មភាពនេះបណ្តាលឱ្យមានការរំខានយ៉ាងខ្លាំង។ ស្រូវឡើងទឹកត្រូវបានគេធ្វើជារៀងរាល់ឆ្នាំនៅប៉ែកខាងជើង និង ខាងកើតតំបន់ IBA នេះ ហើយក្នុងអំឡុងពេលនេះ កន្លែងជាច្រើនក្នុងតំបន់ត្រូវបានគេធ្វើការភ្ជួររាស់ដោយត្រាក់ទ័រ ដែលបង្កឱ្យមានការគំរាមកំហែងដល់សត្វខ្សឹបកំពុងធ្វើសំបុកពងកូន ដោយសារការរំខាន និង ការបំផ្លាញសំបុក ។ ការគំរាមកំហែងនាពេលអនាគតគឺជាការប្រែក្លាយតំបន់វាលស្មៅបន្តទៀតទៅជាតំបន់ស្រូវឡើងទឹក ។

ការគំរាមកំហែងចំបងមួយទៀតគឺជាការបរបាញ់សត្វសម្រាប់ទាំងធ្វើម្ហូប និង លក់ដូរ ដែលបានប៉ះពាល់ដល់សត្វស្លាបទឹក និងខ្សឹប ។ ការប្រមាញ់បានធ្វើឱ្យចំនួនសត្វខ្សឹបថយចុះយ៉ាងខ្លាំងការពីរយៈពេលកន្លងទៅថ្មីៗនេះ ។ ទោះជាយ៉ាងក្តី សកម្មភាពនៃការអភិរក្សអស់រយៈពេលជាងពីរឆ្នាំកន្លងទៅនេះបានធ្វើឱ្យមានការកាត់បន្ថយការបរបាញ់សត្វនៅក្នុងតំបន់នេះ។

**អនុសាសន៍**

ការអនុវត្តន៍ច្បាប់នាពេលថ្មីៗនេះដែលធ្វើឡើងដោយផ្តោតលើការបរបាញ់ និង ការធ្វើពាណិជ្ជកម្មប្រភេទសត្វសំខាន់ៗ ជាពិសេសសត្វខ្សឹប និង សត្វស្លាបទឹកធំៗផ្សេងទៀតគួរតែពង្រឹងឱ្យបានល្អ។

កម្មវិធីផ្សព្វផ្សាយចំណេះដឹងដល់សហគមន៍ពេលថ្មីៗដែលបានធ្វើឡើងនៅក្នុងតំបន់គ្រួសក្រោម និង តំបន់ក្បែរៗគួរតែពង្រីកឱ្យពាសពេញតំបន់នេះទាំងមូល ។

ការសិក្សាស្រាវជ្រាវគួរតែធ្វើឡើងបន្ថែមទៀតដើម្បីស្វែងយល់ពីសារៈសំខាន់អេកូឡូស៊ីនៃតំបន់វាលស្មៅលិចទឹកតាមរដូវកាល និង តំបន់ស្រូវឡើងទឹក ជាពិសេសចំពោះការអភិរក្សសត្វខ្សឹប ។

ការអភិវឌ្ឍន៍កសិកម្មណាមួយ ជាពិសេសការពង្រីកផ្ទៃដីស្រូវឡើងទឹកមិនគួរធ្វើឡើងដោយគ្មានការវាយតំលៃផលប៉ះពាល់បរិស្ថាននោះទេ និង ការស្វែងយល់ឱ្យបានស៊ីជំរៅដល់ប្រភេទទីជំរកដែលមានទំនាក់ទំនងជាមួយនឹងខ្សឹប ដោយសារការប្រែក្លាយប្រព័ន្ធអេកូឡូស៊ីធម្មជាតិទៅជាតំបន់កសិកម្ម។

### ឯកសារយោង


Davidson, P. (2001) A further twelve new species for Cambodia. *Cambodia Bird News* 7: 26-35

Goes, F. ed. (2000) Recent sightings. *Cambodia Bird News* 6: 44-51.

Goes, F. and Davidson, P. eds. (2002) Recent sightings. *Cambodia Bird News* 9: 47-59.

Goes, F., Hong Chamnan, Davidson, P. and Poole, C. M. (2001) *Bengal Florican* Houbaropsis bengalensis *conservation in Kampong Thom province, Cambodia.* Phnom Penh: Wildlife Conservation Society.

Sam Veasna (1999) *Survey for Sarus Crane and other endangered bird species in southern Kampong Thom provi nce, Cambodia*. Unpublished report to the Oriental Bird Club.

Seng Kim Hout *et al.* (2002) *Field survey of seasonally flooded wetlands located in the east of Tonle Sap Lake in Kampong Thom and Siem Reap provinces.* Unpublished report to the Wildlife Conservation Society Cambodia Program and the BirdLife International Vietnam Programme.